ទម្រង់ ពអទ ០២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សម្រាប់មន្ត្រីពន្ធដារ**

ថ្ងៃទី☐☐ខែ☐☐ឆ្នាំ☐☐

លេខចូល ....................................

ហត្ថលេខា ..................................

ឈ្មោះមន្ត្រីពន្ធដារ .........................

**អគ្គនាយកដ្ឋានពន្ធដារ**

**នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

សាខាពន្ធដារខេត្ត-ខណ្ឌ____________

# លិខិតប្រកាស
## ពន្ធលើអចលនទ្រព្យ ប្រចាំឆ្នាំ______

(សូមអានកំណត់ណែនាំនៅផ្នែកខាងក្រោយនៃលិខិតប្រកាសនេះ មុននឹងបំពេញលិខិតប្រកាសនេះ)

### I. ព័ត៌មានអចលនទ្រព្យ

01 លេខអត្តសញ្ញាណកម្មអចលនទ្រព្យ ☐☐☐☐☐☐☐☐☐☐☐

02 - ឯកសារសម្គាល់អចលនទ្រព្យ : លិខិតលេខ ______________________ ចុះថ្ងៃទី _____ ខែ _____ ឆ្នាំ ______ ចេញដោយ ______________________

- អាសយដ្ឋានអចលនទ្រព្យ : លេខ ________________ ផ្លូវ _____________ ភូមិ _______________________ ឃុំ/សង្កាត់ ______________________

ក្រុង/ស្រុក/ខណ្ឌ ________________________________ ខេត្ត/រាជធានី _______________________________________ ។

- ប្រភេទអចលនទ្រព្យ : ១- ☐ ដី ២- ☐ សំណង់: - ☐ បេតុង ( ☐ ផ្ទះ ☐ អគារអាជីវកម្ម )
  - ☐ មិនមែនបេតុង ( ☐ ផ្ទះ ☐ អគារអាជីវកម្ម )
  - ☐ ខុនដូ

### II. ការគណនាប្រាក់ពន្ធលើអចលនទ្រព្យ

| 03 បរិយាយអចលនទ្រព្យ | ដី / សំណង់ | | | | | តម្លៃអចលនទ្រព្យ |
|---|---|---|---|---|---|---|
| | អាយុកាលសំណង់ | | ជាន់ទី(១) | ទំហំ (ម²) | តម្លៃ/ម² (២) | |
| | ដល់១០ឆ្នាំ | លើស១០ឆ្នាំ | | | | |
| 1 | 2 | 3 | 4 | 5 | 6 | 7 = 5 x 6 |
| ១- ដី | | | | | | |
| ២- សំណង់ : | | | | | | |
| - ជាន់ក្រោមដី | | | | | | |
| - ជាន់ផ្ទាល់ដី | | | | | | |
| - ជាន់ទី១ | | | | | | |
| - ជាន់ទី២ - ទី៥ | | | | | | |
| - ជាន់ទី៦ - ទី១០ | | | | | | |
| - ចាប់ពីជាន់ទី១១ ឡើងទៅ | | | | | | |
| **តម្លៃសរុប** | | | | | | |
| **តម្លៃសរុប ៨០%** ( = តម្លៃសរុប x ៨០% ) | | | | | | |
| ដកតម្លៃអចលនទ្រព្យដែលត្រូវបានអនុញ្ញាតឱ្យកាត់បន្ថយ | | | | | | ( ១០០,០០០,០០០រៀល ) |
| មូលដ្ឋានគិតពន្ធ | | | | | | |
| **ប្រាក់ពន្ធត្រូវបង់ = មូលដ្ឋានគិតពន្ធ x 0.១%** | | | | | | |

(១)- សម្រាប់សំណង់ ចំពោះជាន់ទី២ដល់ទី៥ ជាន់ទី៦ដល់ទី១០ និង ចាប់ពីជាន់ទី១១ ឡើងទៅ ត្រូវគិតរួមបញ្ចូលគ្នាទាំងជាន់ និងទំហំ ។

(២)- តម្លៃកំណត់ដោយគណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យដែលបិទផ្សាយនៅតាមឃុំ/សង្កាត់ ឬនៅអង្គភាពពន្ធដារ ដែលអចលនទ្រព្យនោះស្ថិតនៅ ។

### III. ព័ត៌មានម្ចាស់អចលនទ្រព្យ (អ្នកជាប់ពន្ធ)

| 04 ល.រ | ឈ្មោះម្ចាស់អចលនទ្រព្យ | ភេទ | ថ្ងៃខែឆ្នាំកំណើត | លេខលិខិតសម្គាល់ខ្លួន (៣) | អាសយដ្ឋានបច្ចុប្បន្នរបស់ម្ចាស់អចលនទ្រព្យ | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | ផ្ទះលេខ | ផ្លូវ | ភូមិ | ឃុំ/សង្កាត់ | ក្រុង/ស្រុក/ខណ្ឌ | ខេត្ត/រាជធានី |
| | | | | | | | | | | |
| | | | | | | | | | | |
| ទូរស័ព្ទ: | | | | | សារអេឡិចត្រូនិក(E-mail): | | | | | |

(៣)- **សូមគូសក្នុងប្រអប់** ☐ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ☐ សំបុត្របញ្ជាក់កំណើត ☐ សៀវភៅគ្រួសារ ☐ សៀវភៅស្នាក់នៅ ☐ លិខិតបញ្ជាក់ទីលំនៅ ☐ លិខិតឆ្លងដែនសម្រាប់ជនបរទេស

ខ្ញុំបាទ-នាងខ្ញុំសូមធានាថា ព័ត៌មានទាំងអស់នៅលើលិខិតប្រកាសនេះពិតជាត្រឹមត្រូវ និងសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ទាំងឡាយជាធរមាន ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ ។

ធ្វើនៅ__________, ថ្ងៃទី _____ ខែ ______ ឆ្នាំ ________

**ហត្ថលេខា**

កំណត់សម្គាល់ :

១- ម្ចាស់អចលនទ្រព្យ ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធជារៀងរាល់ឆ្នាំជូនរដ្ឋបាលសារពើពន្ធ ក្នុងភូមិសាស្ត្រដែលអចលនទ្រព្យស្ថិតនៅយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំនីមួយៗ ។

២- ម្ចាស់អចលនទ្រព្យ នឹងទទួលរងទោសទណ្ឌទៅតាមច្បាប់ស្តីពីសារពើពន្ធប្រសិនបើ :
- មិនបានដាក់លិខិតប្រកាស បង់ពន្ធខ្វះ បង់ពន្ធយឺត ឬមិនបានបង់ពន្ធ
- ធ្វើការប្រកាសក្លែងបន្លំ

សម្រាប់មន្ត្រីពន្ធដារ

បែបបទនៃការបង់ប្រាក់ : ☐សាច់ប្រាក់ ☐មូលប្បទានប័ត្រ ☐បង្វែរ

ចំនួនទឹកប្រាក់ ......................................................................

បង់តាមបង្កាន់ដៃលេខ........................ចុះថ្ងៃទី......../......../.........

លរ.លន គណនេយ្យកម្ម........................ថ្ងៃធ្វើ......../......../.........

ឈ្មោះមន្ត្រីពន្ធដារ.........................ហត្ថលេខា ..........................

**ឯកសារថតចម្លងត្រូវភ្ជាប់មកជាមួយ**

១- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត ឬលិខិតឆ្លងដែនសម្រាប់ជនបរទេស

២- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ

៣- បណ្ណសម្គាល់សិទ្ធិ ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលចេញដោយរដ្ឋបាលសុរិយោដី ឬឯកសារពាក់ព័ន្ធនឹងការកាន់កាប់អចលនទ្រព្យដែលបញ្ជាក់ដោយអាជ្ញាធរឃុំ/សង្កាត់ឡើងទៅ ។

**កំណត់ណែនាំសម្រាប់បំពេញទម្រង់លិខិតប្រកាសពន្ធលើអចលនទ្រព្យ**

## I. ព័ត៌មានអចលនទ្រព្យ

**ប្រអប់លេខ០១ :**

- **លេខអត្តសញ្ញាណកម្មអចលនទ្រព្យ** : សូមសរសេរលេខអត្តសញ្ញាណកម្មរបស់អចលនទ្រព្យ ។ បើគ្មាន សូមទុកប្រអប់នេះឱ្យនៅទំនេរ ហើយរដ្ឋបាលសារពើពន្ធក្នុងភូមិសាស្ត្រដែលអចលនទ្រព្យរបស់លោក/លោកស្រីស្ថិតនៅ នឹងចេញលេខអត្តសញ្ញាណកម្មជូន ។

**ប្រអប់លេខ០២ :**

- **ឯកសារសម្គាល់អចលនទ្រព្យ** : សូមបំពេញលេខលិខិត ថ្ងៃខែឆ្នាំចេញលិខិត និងស្ថាប័នដែលចេញលិខិតសម្គាល់អចលនទ្រព្យរបស់លោក/លោកស្រី ។ ឯកសារសម្គាល់អចលនទ្រព្យមានដូចជា បណ្ណសម្គាល់សិទ្ធិ ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលចេញដោយរដ្ឋបាលសុរិយោដី ឬឯកសារពាក់ព័ន្ធនឹងការកាន់កាប់អចលនទ្រព្យដែលបញ្ជាក់ដោយអាជ្ញាធរឃុំ/សង្កាត់ឡើងទៅ ។

- **អាសយដ្ឋានអចលនទ្រព្យ** : សូមបំពេញសេចក្តីលម្អិតស្តីពីអាសយដ្ឋានទីតាំងពិតប្រាកដនៃអចលនទ្រព្យរបស់លោក/លោកស្រី ដូចជា លេខផ្ទះ អគារ-ដីឡូត៍លេខ ផ្លូវ ភូមិ ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ ខេត្ត/រាជធានី ។

- **ប្រភេទអចលនទ្រព្យ** : សូមគូសសញ្ញា (✓) ក្នុងប្រអប់ប្រភេទអចលនទ្រព្យដែលជាប្រភេទអចលនទ្រព្យរបស់លោក/លោកស្រី ។ លោក/លោកស្រីអាចគូសលើសពីមួយ ប្រសិនបើមានអចលនទ្រព្យច្រើនដែលមានក្នុងឯកសារសម្គាល់អចលនទ្រព្យតែមួយ ។

## II. ការគណនាប្រាក់ពន្ធលើអចលនទ្រព្យ

**ប្រអប់លេខ០៣ :**

- **បរិយាយអចលនទ្រព្យ** : សូមបំពេញអចលនទ្រព្យដែលជាប់ពន្ធរបស់លោក/លោកស្រី ដូចជា ដី និងសំណង់តាមជាន់ ដូចដែលបានកំណត់ក្នុងលិខិតប្រកាសនេះ ។

- **អាយុកាលសំណង់** : សូមគូសសញ្ញា (✓) ក្នុងកូឡោន "ដល់១០ឆ្នាំ" ប្រសិនបើសំណង់របស់លោក/លោកស្រី ត្រូវបានប្រើប្រាស់អស់រយៈពេលដល់ ១០ឆ្នាំ ។ សូមគូសសញ្ញា (✓) ក្នុងកូឡោន " លើស១០ឆ្នាំ " ប្រសិនបើសំណង់របស់លោក/លោកស្រី ត្រូវបានប្រើប្រាស់អស់រយៈពេលលើស ១០ឆ្នាំ ។

- **ជាន់ទី** : សូមបញ្ជាក់ជាន់ទីប៉ុន្មាននៃសំណង់របស់លោក/លោកស្រី ឧទាហរណ៍ ជាន់ទី៣ ជាន់ទី៤... ជាដើម ។

- **ទំហំ** : សំដៅដល់ផ្ទៃក្រឡារបស់ដី សំណង់ ដោយការគណនា ស្មើនឹង ប្រវែងបណ្តោយ គុណនឹងប្រវែងទទឹង ។ សម្រាប់សំណង់ ចំពោះជាន់ទី២-ទី៥ ជាន់ទី៦-ទី១០ និងចាប់ពីជាន់ទី១១ឡើងទៅ ត្រូវគិតរួមបញ្ចូលគ្នាទាំងជាន់ និងទំហំ ។

- **តម្លៃ/ម$^2$** : សំដៅដល់តម្លៃអចលនទ្រព្យដែលកំណត់ដោយគណៈកម្មការវាយតម្លៃអចលនទ្រព្យ ក្នុងមួយម៉ែត្រក្រឡា ។

- **តម្លៃអចលនទ្រព្យ** : លោក/លោកស្រី ត្រូវគណនាតម្លៃអចលនទ្រព្យដោយខ្លួនឯង ដោយយក តួលេខកូឡោនទី៥ គុណនឹងតួលេខ កូឡោនទី៦ ។

- **តម្លៃសរុប** : គឺជាផលបូកសរុបតម្លៃអចលនទ្រព្យនីមួយៗ ។

- **ដកតម្លៃអចលនទ្រព្យដែលត្រូវបានអនុញ្ញាតឱ្យកាត់បន្ថយ** : ទឹកប្រាក់ដែលបានអនុញ្ញាតឱ្យកាត់បន្ថយគឺ **១០០,០០០,០០០ រៀល** ។

- **មូលដ្ឋានគិតពន្ធ** : គឺជាផលដករវាង តួលេខសរុបរួម និងតម្លៃអចលនទ្រព្យដែលត្រូវបានអនុញ្ញាតឱ្យកាត់បន្ថយ ១០០,០០០,០០០ រៀល ។

- **ប្រាក់ពន្ធត្រូវបង់** : ស្មើនឹងផលគុណរវាងមូលដ្ឋានគិតពន្ធ និងអត្រាពន្ធ ០.១% ។

## III. ព័ត៌មានម្ចាស់អចលនទ្រព្យ (អ្នកជាប់ពន្ធ)

**ប្រអប់លេខ០៤ :**

- **ឈ្មោះម្ចាស់អចលនទ្រព្យ** : សូមបំពេញឈ្មោះម្ចាស់អចលនទ្រព្យដូចដែលមាននៅក្នុងឯកសារសម្គាល់អចលនទ្រព្យ ។ ក្នុងករណីអចលនទ្រព្យមានម្ចាស់លើសពី ១នាក់ឡើងទៅ ត្រូវដាក់ឈ្មោះម្ចាស់អចលនទ្រព្យទាំងអស់ ។ ក្នុងករណីម្ចាស់អចលនទ្រព្យជានីតិបុគ្គល ដូចជា ក្រុមហ៊ុន អង្គការ សមាគម ... ត្រូវដាក់ឈ្មោះក្រុមហ៊ុន អង្គការ សមាគម ... ទាំងនោះ ។

- **លេខលិខិតសម្គាល់ខ្លួន** : សូមបំពេញលេខលិខិតណាមួយដែលលោក/លោកស្រីប្រើ ដើម្បីសម្គាល់អត្តសញ្ញាណដែលមានដូចជា អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ សំបុត្រកំណើត សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ លិខិតបញ្ជាក់ទីលំនៅ លិខិតឆ្លងដែនសម្រាប់ជនបរទេស ហើយសូមគូសនៅក្នុងប្រអប់ដៃ ចំណុចយោង (៣) ដើម្បីបញ្ជាក់ពី ប្រភេទលិខិតសម្គាល់អត្តសញ្ញាណ ។

- **អាសយដ្ឋានបច្ចុប្បន្នរបស់ម្ចាស់អចលនទ្រព្យ** : សូមបំពេញសេចក្តីលម្អិតស្តីពីអាសយដ្ឋានបច្ចុប្បន្នរបស់ម្ចាស់អចលនទ្រព្យ ដូចជា លេខផ្ទះ ផ្លូវ ភូមិ ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ ខេត្ត/រាជធានី ។

- **លេខទូរស័ព្ទ** : សូមបំពេញលេខទូរស័ព្ទផ្ទាល់ខ្លួនរបស់ម្ចាស់អចលនទ្រព្យ ឬអ្នកតំណាង ឬក្រុមគ្រួសារដែលអាចធ្វើការទំនាក់ទំនងបាន ។